# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០៣៧៨/២៣ ន. គ. ស/សរណ.៧.

ថ្ងៃពុធ ១៥កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង

## ស្តីពី

## កាតព្វកិច្ចនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ មកនិយ័តករគណនេយ្យនិងសវនកម្ម

**និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស.) នៃ**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (អ.ស.ហ.) មានកិត្តិយស សូមជម្រាបជូនដល់ **ម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ** ជ្រាបថា÷ អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ (ហៅកាត់ថា អង្គភាព) ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ ស្របតាមស្តង់ដាគណនេយ្យជាធរមាន មក **ន.គ.ស.** តាមពេលវេលាដូចខាងក្រោម÷

**ទី១.** <u>សហគ្រាស និងអង្គភាព ដែលមិនរងសវនកម្មឯករាជ្យ</u> ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** **មិនឱ្យហួសថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៤**។ សហគ្រាស និងអង្គភាពដែលត្រូវបានអនុញ្ញាតឱ្យបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** មិនឱ្យហួសរយៈពេល **៣ខែ បូក ២០ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

**ទី២.** <u>សហគ្រាស និងអង្គភាព ដែលរងសវនកម្មឯករាជ្យ</u> ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មរួចមក **ន.គ.ស.** **មិនឱ្យហួសថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤**។ សហគ្រាស និងអង្គភាពដែលត្រូវបានអនុញ្ញាតឱ្យបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** មិនឱ្យហួសរយៈពេល **៦ខែ បូក ២០ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

*ជាមួយគ្នានេះ ដើម្បីជួយដល់សហគ្រាស និងអង្គភាព អនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មបានត្រឹមត្រូវ ជៀសផុតពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម* ***ន.គ.ស.*** *សូមរំលឹកអំពីកិច្ចការស្នូលមួយចំនួនដែលសហគ្រាស និងអង្គភាព ត្រូវអនុវត្តមានដូចខាងក្រោម÷*

១. ត្រូវកាន់បញ្ជីគណនេយ្យ ឱ្យបានត្រឹមត្រូវ

២. ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន ឱ្យបានរួចរាល់មិនឱ្យហួស **រយៈពេល ៣ខែ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។ ស្តង់ដាគណនេយ្យជាធរមាន សំដៅដល់ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (Cambodia International Financial



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111

Reporting Standards-CIFRS) ឬ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម (Cambodia International Financial Reporting Standards for Small and Medium Sized Entities-**CIFRS for SMEs**) ឬ ស្តង់ដារបាយការណ៍-ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ (Cambodian Financial Reporting Standards for Not-For-Profit Entities-**CFRS for NFPEs**)

៣. ត្រូវបញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្ម លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនឱ្យហួស **រយៈពេល ៦ខែ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ប្រសិនបើសហគ្រាស ឬ អង្គភាពនោះ ស្ថិតក្នុងលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យដូចមានចែងក្នុងប្រកាសលេខ ៥៦៣ សហវ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ។

៤. ត្រូវមានលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុ(FIN) ដើម្បីអាចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន មក **ន.គ.ស.** ដោយត្រូវប្រើប្រាស់ប្រព័ន្ធអនឡាញ (e-filing system)។ សហគ្រាស ឬ អង្គភាព ដែលមិនទាន់មានលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុពី **ន.គ.ស.** ត្រូវស្នើសុំតាមរយៈតំណភ្ជាប់ https://efiling.acar.gov.kh/auth/login ដោយត្រូវអនុវត្តតាមបែបបទ និងនីតិវិធីនៃការប្រើប្រាស់ប្រព័ន្ធអនឡាញ។

៥. ត្រូវដាក់លិខិតស្នើសុំផ្លាស់ប្តូរលេខ FIN មក **ន.គ.ស.** ឱ្យបានមុន **៦០ថ្ងៃ** នៃកាលបរិច្ឆេទផុតកំណត់ដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ ក្នុងករណីសហគ្រាស ឬ អង្គភាពបានប្រែប្រួលការចាត់ថ្នាក់ជាសហគ្រាស ឬ អង្គភាពរងសវនកម្មឯករាជ្យ ឬ មិនរងសវនកម្មឯករាជ្យ។ ការយឺតយ៉ាវក្នុងការស្នើសុំប្តូរលេខ FIN នឹងនាំដល់ការយឺតយ៉ាវនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** ដែលជាកម្មវត្ថុនៃការអនុវត្តពិន័យអន្តរការណ៍។

៦. សហគ្រាស ឬ អង្គភាព ត្រូវបង់កម្រៃសេវាសាធារណៈសម្រាប់ការទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុស្របតាមប្រកាសលេខ ០០១ អ.ស.ហ.ប្រ.ក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម។

៧. សហគ្រាស ឬ អង្គភាព អាចចាត់តាំងអ្នកតំណាងដើម្បីបំពេញកាតព្វកិច្ចគណនេយ្យនិងសវនកម្មជាមួយមន្ត្រី **ន.គ.ស.** បាន។ អ្នកតំណាងអាចជាបុគ្គលិកសហគ្រាស ឬ អង្គភាពផ្ទាល់ ឬជាក្រុមហ៊ុនគណនេយ្យ ឬ ជាក្រុមហ៊ុនសវនកម្មដែលមានអាជ្ញាបណ្ណនៅមានសុពលភាពពី **ន.គ.ស.** ។ រាល់អ្នកតំណាងត្រូវមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវពីម្ចាស់សហគ្រាស ឬ ប្រធានអង្គភាព។ ម្ចាស់សហគ្រាស និងប្រធានអង្គភាពត្រូវទទួលខុសត្រូវទាំងស្រុងចំពោះរាល់សកម្មភាពរបស់អ្នកតំណាងរបស់ខ្លួន។

៨. សហគ្រាស ឬអង្គភាព ត្រូវជ្រើសរើសក្រុមហ៊ុនគណនេយ្យ និង/ឬ សវនកម្មណាមួយ ដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬសវនកម្ម នៅមានសុពលភាព ពី **ន.គ.ស.** ដូចមាននៅក្នុងបញ្ជីភ្ជាប់មកជាមួយនឹងសេចក្តីជូនដំណឹងនេះ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមន្ត្រីរបស់ ន.គ.ស. តាមរយៈប្រព័ន្ធតេឡេក្រាមដូចខាងក្រោម÷**

- សហគ្រាសរងសវនកម្មឯករាជ្យ÷០៧០ ៩២៩ ២៣៧/០៧៧ ៨០៥ ៥៥២/០១០ ៦៩៤ ៦២/០១៦ ៥៩៨ ៣៨៦/០១០ ៧៣៦ ៨៣៥
- សហគ្រាសមិនរងសវនកម្មឯករាជ្យ÷ ០៩៣ ៩១៩ ១៩២/០៩៩ ៤២៩ ៣៩៨/០៧០ ៥៤៥ ៦៨៧/០៧០ ២១២ ២៣៦/០៦៩ ៥១៩ ៣៧១

- អង្គភាព៖ ០៨១ ៦៤៤ ៦៦៣/០៩២ ៦៨៨ ២៩៧/០៨៥ ៩០៤ ៨៤៨/០៨៥ ៤៤៤ ៤៨៨។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និងប្រធានអង្គភាព ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ចាប់ពីពេលនេះតទៅ។

**អគ្គនាយក**

**ប៊ូ ចាវិន**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
សូមចូលរួមក្នុង Telegram Channel របស់និយ័តករគណនេយ្យនិងសវនកម្ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០១៣៧/២៣ ន.គ.ស/ស.ផ.ល

ថ្ងៃពុធ ៨កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## បច្ចុប្បន្នភាពនៃបញ្ជីក្រុមហ៊ុនដែលទទួលបាននីតិសម្បទាផ្តល់សេវាវិជ្ជាជីវៈគណនេយ្យ និង សវនកម្ម

និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា៖ ដើម្បីជួយសម្រួលដល់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញក្នុងការជ្រើសរើសក្រុមហ៊ុនគណនេយ្យ និង/ឬក្រុមហ៊ុនសវនកម្ម សម្រាប់ការផ្តល់សេវាប្រកបវិជ្ជាជីវៈគណនេយ្យ ឬសេវាប្រកបវិជ្ជាជីវៈសវនកម្ម **ន.គ.ស.** សូមផ្តល់ជូននូវបញ្ជីឈ្មោះក្រុមហ៊ុនប្រកបវិជ្ជាជីវៈគណនេយ្យ និងក្រុមហ៊ុនប្រកបវិជ្ជាជីវៈសវនកម្ម ដែលទទួលបានអាជ្ញាបណ្ណពី **ន.គ.ស.** មានដូចខាងក្រោម៖

### I. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត១

| ល.រ | ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ | ឈ្មោះក្រុមហ៊ុនជាអក្សរឡាតាំង | គណនេយ្យករ | លេខសេចក្តីសម្រេច |
|---|---|---|---|---|
| ១ | 3អេស ខនសាល់ធីង ឯ. ក | 3S Consulting Co., Ltd | លោកស្រី ស៊ីម សុធារី | ០០៣/២៣ ន.គ.ស.អ.ជ.គ១ |
| ២ | ហាន់ហ្គោ ស៊ូជីតាក់ & អ៊ីខោនធីង (ខេមបូឌា) | Hongo Tsuji Tax & Accounting (Cambodia) Co., Ltd | Mr. FUJITA YUTAKA | ០១៦៨ ន.គ.ស.ស.ស.រ |
| ៣ | អាខ្លែម (ខេមបូឌា) ឯ.ក | Acclime (Cambodia)Co., LTD | Mr. DAWELL HUGH NICHOLAS | ០២៩ ន.គ.ស.ស.ស.រ |



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ: ០២៣ ៨៨២ ១១១
Phone: 023 882 111

| | | | | |
|---|---|---|---|---|
| ៤ | ស្កាយ លីមីធីត អឹខោនធីង (ខេមបូឌា) ខូអិធីឌី | Sky Limited Accounting (Cambodia) Co., Ltd | Mr. SHIBA KIYOTAKA | ០៣៣ ន.គ.ស.ស.ស.រ |
| ៥ | ឌី អេ អេស & ផាតនើរ ឯ. | D A S & Partners Co., Ltd | លោក រស់ វណ្ណារ៉ា | ០៤៣ ន.គ.ស.ស.ស.រ |
| ៦ | មេគង្គ អឹខោនធីង សឺវីស ឯ.ក | Mekong Accounting Services Co., LTD | Mr. B K NABPN KUMAR | ០០៦/២៣ ន.គ.ស.អ.ជ.គ១ |
| ៧ | ឌីជីថល ហ្វាយនែន ខនសាលធេនស៊ី ឯ.ក | Digital Finance Consultancy Co., LTD | លោក សាយ សុខខេង | ០០២០/២៣ នគសអជគ១ |

II. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យករម្រិត២

| ល.រ | ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ | ឈ្មោះក្រុមហ៊ុនជាអក្សរឡាតាំង | គណនេយ្យករ | លេខសេចក្ដីសម្រេច |
|---|---|---|---|---|
| ១ | រៀល ប៊ីហ្សនេស ខនសាល់ថេសិន | Real Business Consultation Co., Ltd | លោកស្រី គុយ ខាឃីម | ០០៤/២៣ នគសអជគ២ |
| ២ | ឡា ប៉េ ផាតនើរ & អាសូស៊ីអេត ឯ.ក | La Paix Partners & Associates Co., Ltd | -លោក ឈៀង ធារិទ្ធ<br>-លោក អ៊ា វីរៈ | ០០៧/២៣ នគសអជគ២ |
| ៣ | អេសអេសភីអឹម ខនសាល់ធីង សឺវីស ឯ.ក | SSPM Consulting Services Co., Ltd | លោក ស្រ៊ុង ម៉ុងដែន | ០០៩/២៣ នគសអជគ២ |
| ៤ | ត្រាស់អេជ ខន់សាល់ធីង ឯ.ក | Trustedge Consulting Co., Ltd | លោក ហេង រដ្ឋា | ០១០/២៣ នគសអជគ២ |
| ៥ | អ៊ែតខេម ខនសាល់ធី | ATCAM Consulting Co., Ltd | លោកស្រី នុច គឹមលីន | ០១១/២៣ នគសអជគ២ |
| ៦ | អ៊ីហ្គល ខេមប៊ីស ខនសាល់ធេន ឯ.ក | Eagle Cambus Consultant Co., Ltd | លោក សោម ភារិទ្ធ | ០១៤/២៣ នគសអជគ២ |
| ៧ | ខេឌី ខនសាល់ធេន ឯ.ក | KD Consultants company Limited | លោកស្រី ជា ច័ន្ទកក្កដា | ០០១៦/២៣ នគសអជគ២ |
| ៨ | រ៉ូយ៉ាល់ ស៊ីធីអេ (ខេមបូឌា) ខូ អិលធីឌី | Royal CTA (Cambidia) Co., Ltd | លោក នៅ នឿន | ០០១៧/២៣ នគសអជគ២ |

III. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម

| ល.រ | ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ | ឈ្មោះក្រុមហ៊ុនជាអក្សរឡាតាំង | គណនេយ្យ និងសវនករ | លេខសេចក្ដីសម្រេច |
|---|---|---|---|---|
| ១ | ប៊្លូ ឆាធើរ អឹខោនថិន អេន អឌីតធ័រ ឯ.ក | Blue Chartered Accountants and Auditors Co., Ltd | លោក គង់ ស៊ិនរ៉ា | ០១៧ ន.គ.ស./ស.ស.រ |
| ២ | អ៊ីស្ត វីង អឌីធីង & ខនសាល់ធីង | East Wing Auditing & Consulting Co., Ltd | Mr. KOH BENG LEONG | ០០៥/២៣ នគសអជស |

| | | | | |
|---|---|---|---|---|
| ៣ | វីប៊ីធី អេន ផាតនើរ ឯ.ក | VBT and Partners Co., Ltd | លោក វង ប៊ុនធឿន | ០០២/២៣ នគសអជស |
| ៤ | អេកូវីស វីអេសឌីខេ & ផាតនើរ ឯ.ក | ECOVIS VSDK & Partner Co., Ltd | -លោក ប៊ិល សុភ័ក្រ<br>- លោក តឹក សុខវាសនា | ០០៧/២៣ ន.គ.ស.អ.ប |
| ៥ | ភី អេ ធីប្រូហ្វេសិនណលលីមីធីត | P A T Professional Limited | លោក ស៊ា ពិសិដ្ឋ | ០០៤/២៣ ន.គ.ស.អ.ប |
| ៦ | ខេម អឹខោនធីង & ថាក សឺវីស ឯ.ក | Cam Accounting & Tax Service Company Limited | លោក ស៊ឹម ហ៊ុយឈ័ង | ០០៦/២៣ ន.គ.ស.អ.ប |
| ៧ | អេស អិម គ្លូប៊ល អឹខោនធីង & ខនសាលធីង | SM Global Accounting & Consulting Co., Ltd | លោក ហូ សុខហួរ | ០០៥/២៣ ន.គ.ស.អ.ប |
| ៨ | ផេក ខនសាល់ធីង ឯ.ក | PAC Consulting Company limited | លោក ប៉ោល មករាទិត្យាស័ក្ក | ០៣៩ ន.គ.ស.ស.ស.រ |
| ៩ | អេធីអេភី &ផាតនើរ ឯ.ក | ATAP & Partners Company Limited | លោក ប៉ែន ទីម៉ុល | ០៣៧ ន.គ.ស.ស.ស.រ |
| ១០ | រីចធ៍ & ផាតនើរ | Reachs & Partners Co., Ltd | -លោក រឿន ប៊ុនហេង<br>-លោក អេ ប៊ុនថេត | ០៣០ ន.គ.ស.ស.ស.រ |
| ១១ | ហ្វូណន ខនសាល់ធីង ឯ.ក | Funan Consulting Co., Ltd | Mr.PALANARATNAGE<br>SENAKA DIHAN<br>FERNANDO | ០៣១ ន.គ.ស.ស.ស.រ |
| ១២ | អេសស៊ីអេស គ្លូប៊ល ខនសាល់ធីង (ខេមបូឌា) | SCS Global Consulting (Cambodia) Co., Ltd | Mr. MIYATA TOMOHIRO | ០៣៥ ន.គ.ស.ស.ស.រ |
| ១៣ | ឌីឡយធ៍ (ខេមបូឌា) ខូ អិលធីឌី | Deloitte (Cambodia) Co., Ltd | -លោក ខូយ គីមលេង<br>-លោក អ៊ឹង គឹមសុភ័ត្រា<br>-លោកស្រី ឈីវ គឹមស្រួយ | ០២៣ ន.គ.ស.ស.ស.រ |
| ១៤ | វី ឆាធើរ អឹខោនថិន | V Chartered Accountants Co., Ltd | - Mrs. SORIANO<br>PRISCILLA PALAD | ០២៥ ន.គ.ស.ស.ស.រ |
| ១៥ | អឹផឡូ អ៊ិនវេសម៉ិន & ខនសាល់ធីង ឯ.ក | Apollo Investment & Consulting Co., Ltd | លោក សាន្ត ចន្ទកុម្ភៈ | ០២៤ ន.គ.ស.ស.ស.រ |
| ១៦ | ចន្ទ & អឹសូស៊ីអេត | Chan & Associates Co., Ltd | លោក ឈរ ឆេង | ០២៨ ន.គ.ស.ស.ស.រ |
| ១៧ | អាល់នីសុន អឌីធីង អេន ខនសាល់ធីង | Allnison Auditing and Consulting Co., Ltd | Mr. LO TIK | ០២២ ន.គ.ស.ស.ស.រ |

| | | | | |
|---|---|---|---|---|
| ១៨ | ប្រាយវ៉តធ័រ ហាវខូភើស៍ (ខេមបូឌា) | PricewaterhouseCoopers (Cambodia) Ltd | -លោក គុយ លឹម<br>-លោកស្រី ហង្សសូផាត ម៉ូលីហ្សាណា<br>-លោកស្រី ទូច សុវណ្ណារ៉ា<br>-លោក ឡាង ហ៊ី<br>- Mrs. BENIDA FERNANDO | ០១៦៧ ន.គ.ស.ស.ស.រ |
| ១៩ | ខេ ភី អឹម ជី ខេមបូឌា | KPMG Cambodia Ltd | -លោក ង៉ែ ហ៊ុយ<br>-លោកស្រី ហ្គេក ទាវ<br>-កញ្ញា តាំង យុកហ៊ុង<br>-លោក ភូ សុទ្ធី<br>-លោក យឹម ឡុងឌី<br>-លោកស្រី សូ ដារី<br>- Mr. PHOR AUVARIN<br>- Mr. LOW SHE KIT | ០១៦៤ ន.គ.ស.ស.ស.រ |
| ២០ | ហ្វីដេស សឺវីស (ខេមបូឌា) លីមីធីត | FIDES Services Cambodia Ltd | -លោកស្រី ជុង រ៉ានី<br>-លោក ជុង ចិត្តា | ០១០ ន.គ.ស.ស.ស.រ |
| ២១ | អិន អេ អេស | NAS Co., Ltd | -លោក ស្រ៊ុន អង្គារ៉ា<br>-លោក ស្រ៊ុន ចាន់តូរី | ០១៦៣ ន.គ.ស.ស.ស.រ |
| ២២ | អឺន្នស៍ អ៊ែន យ៉ាំង (ខេមបូឌា) | Ernst & Young (Cambodia) Ltd | -លោក ខាវ ហុង<br>-លោកស្រី ឡូន ស៊ីនរតនា<br>- Mr. EMMANUEL ALALID GUELAS<br>- Mrs. MARIA CRISTINA M. CALIMBAS | ០០៨ ន.គ.ស.ស.ស.រ |
| ២៣ | វ៉ូរី អេខោនធីង ខូ អិលធីឌី | Woori Accounting Co., Ltd | Mr. KOH DONG HOO | ០១៩ ន.គ.ស.ស.ស.រ |
| ២៤ | អិល អ អេស ហេនឌើសិន (ខេមបូឌា ) | LRS Henderson (Cambodia) Co., Ltd | Mr. ANDREW NEEDHAM | ០១៦៦ ន.គ.ស.ស.ស.រ |

| | | | | |
|---|---|---|---|---|
| ២៥ | ដូណាស្គូ & ខមភេនី អិលធីឌី | Donasco & Company., Ltd | - Mr. JUNRO LAWIAN BINAG<br>- Mr. RONALD APASO DONASCO | ០០៣ ន.គ.ស.ស.ស.វ |
| ២៦ | បេក ឃើរ ធីលលី (ខេមបូឌា) ឯ.ក | Baker Tilly Cambodia Co., Ltd | -លោក តាន់ គីម៉េង<br>-Mr.TEH CHAY HAW -លោក ពៅ ដារ៉ា | ០១៣ ន.គ.ស.ស.ស.វ |
| ២៧ | ក្រូវ (ខេអេច) ឯ.ក | Crowe (KH) Co., Ltd | - Mr. CHAN KUAN CHEE<br>- Mr. ONN KIEN HOE<br>- Mr. POON YEW HOE | ០០៧ ន.គ.ស.ស.ស.វ |
| ២៨ | រីនដា អិល អិល ខេ ជី (ខេមបូឌា) | Reanda LLKG (Cambodia) Co., Ltd | - Mr. NEOH BOON TOE<br>- Mrs. NEOH BOON GAIK<br>- Mr. KOONG LIN LOONG | ០២១ ន.គ.ស.ស.ស.វ |
| ២៩ | ប៊ី ឌី អូ (ខេមបូឌា) លីមីធីត | BDO (Cambodia) Limited | -កញ្ញា សុង ស្រីវឌ្ឍា<br>- Mr. LIM SENG SIEW<br>- Mr. LEE KEN WAI | ០១៦៥ ន.គ.ស.ស.ស.វ |
| ៣០ | អេនឌ្រូ & ហ្វីលីព អឹខោនធីង | Andrew & Philip Accounting Co., Ltd | - Mr. LEE HANA | ០០៩ ន.គ.ស.ស.ស.វ |
| ៣១ | ភីខេអេហ្វ ខូវេណិនថ៍ អិលធីឌី | PKF Covenant Co., Ltd | - Mr. CHEW CHONG EU | ០៤១ ន.គ.ស.ស.ស.វ |
| ៣២ | ប៊ីជី អាសូស៊ីអ៊ីត | BG Associates Ltd | កញ្ញា យឹម ណារី<br>លោក ហុង ពិសិដ្ឋ<br>កញ្ញា ថ្លាង ស៊ីវឆេង | ០០៥ ន.គ.ស.ស.ស.វ |
| ៣៣ | អេភីវី (ខេមបូឌា) ខូ អិលធីឌី | APV (Cambodia) Co., Ltd | Mrs. MARIA ISLABELITA MANZON CABRERA | ០០២ ន.គ.ស.ស.ស.វ |
| ៣៤ | ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត | Grant Thornton (Cambodia) Ltd | - Mr. NG YEE ZENT<br>- Mr. RONALD CRONEL ALMERA | ០០៤ ន.គ.ស.ស.ស.វ |

| | | | | |
|---|---|---|---|---|
| ៣៥ | ខេ ប្រឹហ្វេសិនណល អ៊ីខោនថិន | K Professional Accountants Co., Ltd | លោក ឃុន ដារិទ្ធ | ០១៥/២៣ នគសអជស |
| ៣៦ | សឡូម៉ិន អ៊ីខោនធីង & ខនសាល់ធីង | Solomon Accounting & Consulting Co., Ltd | - Mr. AN KIO BYUNG | ០១១ ន.គ.ស.ស.ស.រ |
| ៣៧ | អេហ្វអាយអាយ & អឹសូស៊ីអេត | Fii & Associates Co., Ltd | -កញ្ញា ហេង សិតា<br>-លោកស្រី ឈុន ម៉ារ៉ា<br>-លោក សេង ចាន់ថន | ០០៦ ន.គ.ស.ស.ស.រ |
| ៣៨ | ឡូចន្ទ&ខូ (ខេមបូឌា) ឯ.ក | Lochan & Co (Cambodia) Company Limited | Mr. PARIHAR BABULAL MANNARAM | ០១៦ ន.គ.ស.ស.ស.រ |
| ៣៩ | អ៊ែតវ៉ានស៍ ហ្គ្រេន ហ្វ័រម៉ូឡា ឯ.ក | Advance Grand Formula Co., Ltd | លោក ហេង គិតសុផល | ០១៤ ន.គ.ស.ស.ស.រ |
| ៤០ | ញូសាញ ខន សាល់ធីង ឯ.ក | New Shine Consulting Co., Ltd | Mr.WANG JIAN | ០៣២ ន.គ.ស.ស.ស.រ |
| ៤១ | យ៉ុងអាន អ៊ិនធើណេសិនណល | Yongan International Consulting Co., Ltd | Mr. PEROL FRANCISO OLARTE | ០៣៦ ន.គ.ស.ស.ស.រ |
| ៤២ | ខ្វន ថឹម& ស្ពេកត្រឹម ឯ.ក | Quatum & Spectrum Co., Ltd | លោក ជៀម គីមហួ | ០០១/២៣ ន.គ.ស.អ.ប |
| ៤៣ | សូតា ប្រឹហ្វេសិនណល ឯ.ក | Sota Professional Company Limited | -លោក ហ៊ិន កុសលា<br>-លោក គិត ចាន់ថង(គណនេយ្យករ កម្រិត២) | ០០១/២៣ នគស/អជស |
| ៤៤ | ដូហ្វូ ឆាធើរ អ៊ីខោនថិន (ខេមបូឌា) ឯ.ក | Doho Chartered Accountants (Cambodia) Co., Ltd | Mr. MAK LEUNG HEI | ០០៨/២៣ ន.គ.ស/អ.ប |
| ៤៥ | បារុន(ខេមបូឌា) អ៊ីខោនធីង&ខនសាល់ធីង ឯ.ក | Barun (Cambodia) Accounting &Consulting Co., Ltd | Mr. KIM KWANG HWAN | ០០៨/២៣ នគស/អជស |

**បញ្ជាក់:**

១. ក្រុមហ៊ុនក្នុងចំណុច I ,II ខាងលើ ពុំមានសិទ្ធិផ្តល់សេវាប្រកបវិជ្ជាជីវៈសវនកម្មឡើយ។

២. ក្រុមហ៊ុនក្នុងចំណុច III ខាងលើ មានសិទ្ធិជាស្វ័យប្រវត្តិក្នុងការផ្តល់សេវាប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម។

៣. ក្រុមហ៊ុនគណនេយ្យ និង/ឬសវនកម្ម ទាំងឡាយណាដែលពុំមានអាជ្ញាបណ្ណពីនិយ័តករគណនេយ្យនិងសវនកម្ម ត្រូវបានហាមឃាត់ក្នុងការផ្តល់សេវាគណនេយ្យ និង/ឬសវនកម្ម និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ទៅ ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន)រៀល ទៅ ៨ ០០០ ០០០(ប្រាំបីលាន)រៀល ឬមានទោសទណ្ឌផ្សេងទៀត ដូចមានចែងក្នុងមាត្រា៣៤ នៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ន.គ.ស.** នឹងធ្វើបច្ចុប្បន្នភាពឈ្មោះក្រុមហ៊ុនប្រកបវិជ្ជាជីវៈគណនេយ្យ និងក្រុមហ៊ុនប្រកបវិជ្ជាជីវៈសវនកម្ម ជាបន្តបន្ទាប់ជូនម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជន ដើម្បីជ្រាបជាព័ត៌មាន។

សម្រាប់ព័ត៌មានបន្ថែម សូមអញ្ជើញមកកាន់ទីស្នាក់ការនិយ័តករគណនេយ្យនិងសវនកម្ម ដែលមានអាសយដ្ឋានស្ថិតនៅផ្លូវ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ អគារ (ក) ជាន់ទី១ (ក្នុងបរិវេណទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ឬទាក់ទងតាមទូរស័ព្ទឬតេឡេក្រាមលេខ ០៩៦ ២២២២ ៦៥៩ ឬអ៊ីមែល: s.soem@acar.gov.kh។

អាស្រ័យហេតុនេះសូមម្ចាស់សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។

**និយ័តករគណនេយ្យនិងសវនកម្ម**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
សូមចូលរួមក្នុង Telegram Channel របស់
និយ័តករគណនេយ្យនិងសវនកម្ម